# ការអនុវត្តន៍ល្អ

## ការគ្រប់គ្រងស្តុកក្នុងឃ្លាំងសំភារៈជំនួយ

រោងចក្រកាត់ដេរ កាន់តែប្រសើរ នៅកម្ពុជា

រោងចក្រកាត់ដេរ ចំណាយការវិនិយោគយ៉ាងច្រើនលើសលប់លើក្រណាត់ ។ ឃ្លាំងដែលមានការរៀបចំល្អនិងប្រព័ន្ធសន្និធិ ដែលដាក់ផ្លាកសំគាល់និងមានឯកសារតាមដានស្តុកទាំងអស់ ដែលជួយគ្រប់គ្រងការវិនិយោគទៅលើសន្និធិទាំងនេះ បង្កើនផលិតភាព និងកាត់បន្ថយចំណាយថ្លៃដើម ។ សូមមើលសេចក្តីណែនាំការអនុវត្តន៍ល្អស្តីពី ការស្តុកក្រណាត់ និងការរៀបចំឃ្លាំង ។

### ការអនុវត្តន៍ល្អសំរាប់ការស្តុកសំភារៈជំនួយ

បែងចែក និងដាក់ផ្លាកសំគាល់ស្តុកចាស់ និងថ្មីទាំងអស់ ( រូបភាពទី១ ) ។

ដាក់ផ្លាកសំគាល់សំភារៈជំនួយ និងបែងចែកវាទៅតាមប្រភេទ ( រូបភាពទី២ ) ។

ប្រើប្រាស់ និងបិទប័ណ្ណសំគាល់ស្តុកលើក្រណាត់ទាំងអស់ ។ ប័ណ្ណសំគាល់ស្តុកធ្វើអោយមានភាពងាយស្រួលផង ដែរក្នុងពេលបញ្ជាទិញ និងពេលរាប់ស្តុក ( រូបភាពទី៣ ) ។

តាមដានថាតើស្តុកណាមួយត្រូវបានប្រើនៅក្នុងផលិតកម្ម និងកាលបរិច្ឆេទដែលស្តុកត្រូវបានយកទៅប្រើប្រាស់ ។


រូបភាពទី១


រូបភាពទី២



រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បង្កើនផលិតភាព តាមរយៈកាត់បន្ថយពេលវេលាស្វែងរកក្រណាត់ និងពេលវេលារាប់ស្តុក
- ✓ កាត់បន្ថយចំណាយថ្លៃដើម ដោយបង្ការមិនអោយមានការបញ្ជាទិញដែលមិនចាំបាច់
- ✓ កាត់បន្ថយចំណាយថ្លៃដើម ដោយកាត់បន្ថយចំនួនស្តុកដែលខូចដោយសារការរក្សាទុកមិនបានល្អ
- ✓ ធ្វើអោយការបញ្ជាសន្និធិកាន់តែលឿន និងកាន់តែងាយស្រួល
- ✓ បង្ករលក្ខណៈងាយស្រួលអោយមានការផលិតសំលៀកបំពាក់ចេញពីបាច់ក្រណាត់តែមួយ ដែលធានាបាននូវភាពស្របគ្នាខាងពណ៌ និងគុណភាពសាច់ក្រណាត់

### តាមរបៀបណា:

- ✓ បង្កើតប្រព័ន្ធប័ណ្ណសំគាល់ស្តុក ដើម្បីសំគាល់សំភារៈជំនួយតាមដុំ ទទឹង បាច់ ស្លាយ ឡូត និង ពណ៌
- ✓ បង្កើតប្រព័ន្ធតាមដានក្រណាត់ដែលប្រើប្រាស់នៅក្នុងផលិតកម្ម
- ✓ ធានាថាប្រធាន និងបុគ្គលិកឃ្លាំងរោងចក្រទទួលខុសត្រូវក្នុងការស្តុក ចែកចាយ និងតាមដានការប្រើប្រាស់ក្រណាត់

### តំលៃ:

$

$ តំលៃទាប

$$ តំលៃមធ្យម

$$$ តំលៃខ្ពស់